


# ប្រទេសកម្ពុជា៖មហាគ្រោះថ្នាក់ដល់ស្លាប់នៃ

# ភាពមិនអាចវិលត្រឡប់ក្រោយនៃយួនូបនីយកម្ម

# & បដិវត្តន៍ផ្កាឈូក!

***បងប្អូនរួមជាតិជាទីគោរព!***

មហាគ្រោះថ្នាក់ដល់ស្លាប់ ដែលប្រជាពលរដ្ឋខ្មែរត្រូវវាយកំចាត់ជាបន្ទាន់ គឺភាពមិនអាចត្រឡប់ក្រោយវិញ បាននៃ ការកាត់ យកទឹកដីខ្មែរពីសំណាក់ប្រទេសយួន។ វានៅមិនទាន់ហួសពេលនៅឡើយទេ ដែលប្រជាពលរដ្ឋត្រូវធ្វើ ៖ ទី១៖ ដោយការរំលំរបបបក្សប្រជាជនហ៊ុនសែន តាមរយៈ បដិវត្តន៍ ឱ្យបានមុនដំណាច់ ឆ្នាំ២០១២ ដែលជា កាលបរិច្ឆេទ ដែលប្រទេសយួននិង របប បក្សប្រជាជនគ្រោងនឹងបញ្ចប់ការ បោះបង្គោល ៣៧៥ ឱ្យហើយដើម្បីកំរិតព្រំដែនថ្មី ប្រវែង១២៧០គម រវាង ប្រទេស ទាំង ពីរ។ ទី២៖ បើពុំអាចរំលំរបបផ្តាច់ការឱ្យបានទាន់ពេលវេលាទេ ប្រជាពលរដ្ឋ ត្រូវតែអនុវត្ត មហាពហិការ ជាទូទៅលើការ បោះឆ្នោតថ្ងៃ២៨កក្កដា២០១៣ ដើម្បីទប់ស្កាត់ ឈប់ផ្តល់និតិបពាត្តិឱ្យបក្សប្រជាជនហ៊ុនសែន។

## ១, មហាគ្រោះថ្នាក់ដល់ស្លាប់ ឬ ភាពមិនអាចត្រឡប់ក្រោយនៃយួនូបនីយកម្ម

វាបណ្ដាលមកពី ភាពល្ងីល្ងើនៃអ្នកដឹកនាំខ្មែរក្បត់ជាតិគ្រប់ទិសទី។ ពីព្រោះថា ឆ្លៀតឱកាសដែលគេចូលលុកលុយប្រទេសកម្ពុជា នៅចុងឆ្នាំ១៩៧៨ មកដល់ ដើមឆ្នាំ១៩៧៩ ប្រទេសយួនបានបង្ខំ ឱ្យក្រុម ប៉ែនសុវ៉ាន់ ហេងសំរិន ជាស៊ីម ហ៊ុនសែន,,, ទទួលយក សន្ធិសញ្ញា ៤:

១ / សន្ធិសញ្ញា សន្តិភាព មិត្តភាព និងសហប្រតិបត្តិការ ចុះ ថ្ងៃ១៨កុម្ភះ ឆ្នាំ១៩៧៩ ដែលមានថេរះវេលា ២៥ឆ្នាំ រួចហើយ បន្ត១០ឆ្នាំម្ដងៗ បើគ្មានភាគីណាជំទាស់សុំបញ្ឈប់ នោះទេ ដែលមាន ចុះហត្ថលេខាដោយ ផាំវ៉ាន់ដុង នាយករដ្ឋមន្ត្រីយួន និង ហេងសំរិន ប្រធានក្រុមប្រឹក្សាបដិវត្តន៏នៃប្រជាជននៃសាធារណរដ្ឋកម្ពុជា។

២/ សន្ធិសញ្ញា ថ្ងៃ៧កក្កដាឆ្នាំ១៩៨២ ស្ដីពី តំបន់ដែនទឹក និង ដែនទឹកប្រវត្តិសាស្ត្រ ចុះហត្ថលេខាដោយ ង្វៀងកូថាច់ និង ហ៊ុនសែន ទាំងពីរអ្នកជារដ្ឋមន្ត្រីការបរទេស នៅទីក្រុងហូជីមិញ។ នៅក្នុងសន្ធិសញ្ញានេះ កម្ពុជា បាន បាត់បង់ កោះត្រល់ និង ប្រជុំកោះក្រចកសេះ ឬ ពូឡូពុនជាង ព្រមទាំង វិសាលភាពសមុទ្រ ៣ ម៉ឺនគីឡូម៉ែត្រការេ (គម២) និង តំបន់ទឹកប្រវត្តិសាស្ត្រ ១ម៉ឺនគីឡូម៉ែត្រការ៉េ ទៀត។ ប្រទេសសាំងហ្គាពួរ បានប្រឆាំងមិនទទួលស្គាល់សន្ធិសញ្ញានេះ ទេ នៅក្នុងលិខិតមួយដែល គេបាន បញ្ជូនទៅឱ្យអង្គការសហប្រជាជាតិ នៅ ថ្ងៃ៥ធ្នូឆ្នាំ១៩៨៦។ ដោយយោងតាមសន្ធិសញ្ញានេះ ប្រទេសយួន និង ប្រទេសសៀម បានសំរេចចុះសន្ធិសញ្ញាមួយដើម្បីបែងយកដែនទឹកកម្ពុជាចែកគ្នាម្នាក់ៗម្នាក់ៗ មួយភាគបី(១/៣) នៃដែនសមុទ្រខ្មែរ ដែលមាន ទំហំ ៩៥ ០០០គម២ នៅថ្ងៃ១១សីហាឆ្នាំ១៩៩៧។ ហ៊ុនសែនបានតវ៉ា ដែរតែយឺតពេល នៅ ថ្ងៃ ៧ឧសភាឆ្នាំ១៩៩៨។

៣/ សន្ធិសញ្ញាថ្ងៃ២០កក្កដា១៩៨៣ ស្ដីពី គោលការណ៍នៃដំណោះស្រាយបញ្ហាព្រំដែន និង កិច្ចព្រមព្រៀង ស្ដី ពី លក្ខន្តិកៈ នៃតំបន់ព្រំដែន ចុះហត្ថលេខាដោយ ង្វៀងកូថាច់ និង ហ៊ុនសែន នៅភ្នំពេញ។

៤/ សន្ធិសញ្ញាថ្ងៃ២៧ធ្នូ១៩៨៥ ស្ដីពី ការគូសកំណត់ព្រំប្រទល់ជាតិ ចុះហត្ថលេខាដោយ ង្វៀងកូថាច់ និង ហ៊ុនសែន នៅភ្នំពេញ ដោយយកមកប្រើនូវផែនទី១/១០០០០០ និង ផែនទី ១/៥០ ០០០ ដែលផ្ទុយពីអ្វីដែលមានចែងក្នុងរដ្ឋធម្មនុញ្ញខ្មែរ ឆ្នាំ១៩៩៣។

ការលុបចោលនូវសន្ធិសញ្ញាខ្មែរយួនទាំង៤នេះត្រូវតែធ្វើឱ្យបានរួចរាល់ពីឆ្នាំ១៩៩៣ មកម៉្លេះ ក្រោយពេលដែល ប្រទេសកម្ពុជា យើងមានស្ដេច មានរាជរដ្ឋាភិបាល និង ស្ថាប័ននានា ដូចសភាជាតិ និង ព្រឹទ្ធសភា ជាដើម ស្របតាមច្បាប់ រដ្ឋធម្មនុញ។ ក៏បន្តែ គួរឱ្យស្ដាយណាស់ ដោយ អ្នកដឹកនាំ ខ្មែរជាជនក្បត់ជាតិ នេះហើយ ទើបយើងពុំបានឃើញការ លុប ចោល សន្ធិសញ្ញានេះ នៅឡើយទេ។ ហ៊ុនសែនបានព្រមានថានឹងរំលំចោលរាជានិយមទី២នេះ ទៀតផង បើ ស្ដេចសីហមុនីមិន ចុះ ហត្ថលេខាលើ សន្ធិសញ្ញាបំពេញបន្ថែម២០០៥ ដើម្បីផ្ដល់សុពលភាពលើសន្ធិសញ្ញាចាស់ៗ ទាំងនោះទេ។

២១ឆ្នាំ បន្ទាប់ពីកិច្ចព្រមព្រៀងប៉ារីសថ្ងៃ២៣តុលា១៩៩១ និង យោងតាម ន័យសង្ខេបដែលមានចែងនៅក្នុង កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសថ្ងៃ២៣តុលា១៩៩១:

ជំពូក១/ ប្រទេសកម្ពុជាត្រូវលុបសន្ធិសញ្ញានានាចោលដើម្បីការពារអធិបតេយ្យភាពរបស់ខ្លួន។

ជំពូក២/ ប្រទេសហត្ថលេខីដទៃទៀតមាន យួននិងសៀមត្រូវតែគោរពអធិបតេយ្យភាពខ្មែរ។

ជំពូក៣ / ប្រទេសកម្ពុជាត្រូវគោរពសិទ្ធិមនុស្ស។

ជំពូក៤ / ប្រទេសហត្ថលេខីមិនត្រូវបណ្តោយឱ្យប្រទេសណាមួយរំលោភប្រទេសកម្ពុជាទេ។

ជំពូក៥ / ក្នុងករណីឈ្លានពានទឹកដីនិងរំលោភសិទ្ធិមនុស្ស ប្រទេស ហត្ថលេខី និង សហប្រធាន ត្រូវចាត់វិធានការដើម្បីដោះស្រាយដោយ សន្តិវិធី ឬត្រូវ ប្តឹងទៅអង្គការសហប្រជាជាតិនិងក្រុមប្រឹក្សាសន្តិសុខនៃ អង្គការសហប្រជាជាតិ។

ប្រជាពលរដ្ឋខ្មែរកំពុងមើលឃើញយ៉ាងជាក់ស្តែង ថា អ្នកដឹកនាំខ្លួន បានក្បត់ខ្លួន ដោយពុំបាន គោរពតាមជំពូក ទាំងប្រាំនៃកិច្ចព្រមព្រៀង នេះទេ។ ផ្ទុយទៅវិញ ទោះជាគេជា អ្នករាជានិយម ឬ ជាជនកុម្មុយនិស្ត ក៏គេនៅតែ គិត ប្រយោជន៍ផ្ទាល់ខ្លួនរបស់គេ ដដែលៈ

១/-បង្កើតរាជានិយមទី២ សំរាប់អ្នករាជានិយម និងសីហនុ

២/- ក្តោបក្តាប់អំណាចទាំងអស់ សំរាប់ជនកុម្មុយនិស្ត និង ហ៊ុនសែន

ហើយទាំងអស់គ្នាបានក្លាយជា កញ្ជះ និង អាយ៉ងយួនទាំងអស់គ្នា ទោះជាចង់ឬមិនចង់ក៏ដោយ។

## ២- ភាពច្របូកច្របល់ នៃ នយោបាយរាជាកុម្មុយនិស្តខ្មែរក្រហម

បន្ទាប់ពីមានការចោទប្រកាន់ជាចំហរ និង ជាបន្តបន្ទាប់របស់ខ្មែរទូទៅ ស៊ីសុវត្ថិធម្មិកោ នៃលេខាធិការដ្ឋាន ស្តេចសីហនុ ដែលជា បុគ្គលម្នាក់ ទទួលលាភសក្ការៈពីរាជានិយមខ្មែរដែរនោះ បានថ្លែងបញ្ជាក់ទទួលស្គាល់ ថាគួរកុំចោទហ៊ុនសែន ថាជាជនក្បត់ ជាតិម្នាក់ឯង។ ពីព្រោះនៅមានអ្នកដឹកនាំនយោបាយខ្មែរសំខាន់ៗ ជាច្រើនទៀតដែរ ចាប់ពីឆ្នាំ១៩៩៣មក។ នេះ គឺត្រូវដូចអ្វីៗ ដែល បដិវត្តិ ផ្កាឈូក បានអះអាងជាយូរយារណាស់មកហើយ! តំណាងរាស្ត្រ គិម សុផារិទ្ធ នៃ គណបក្សសមរ៉ាំងស៊ី បានបដិសេដ្ឋ ចោល ការចោទ ប្រកាន់ មិនរើសមុខបែបនេះ ដើម្បីការពារលោក សមរ៉ាំងស៊ី ដោយយកលេសថា អ្នកទទួលខុសត្រូវសំខាន់ៗ ជំនាន់ នោះ គឺ រ៉ាណារិទ្ធ និង ហ៊ុនសែន,,,។

បន្ទាប់ពីមានប្រតិកម្មពីគ្រប់ទិសទី ផ្តន្ទាអំពើក្បត់ជាតិរបស់ ហ៊ុនសែន ដែលខំមកបំភ្លឺនិយាយដោះស្រាយតែម្នាក់ឯង នៅរដ្ឋសភា ពី ថ្ងៃ៩សីហាឆ្នាំ២០១២មក មេដឹកនាំរាជាកុម្មុយនិស្តខ្មែរសំខាន់ៗពីឆ្នាំ១៩៩៣ ហ៊ានបំពងសំឡេងដើម្បីលាងកំហុសខ្លួនឯងផង និង ដើម្បី ចោទប្រកាន់គ្នាទៅវិញទៅមកផង។ គេទាំងអស់គ្នាកំពុងតែទទួលស្គាល់កំហុសរបស់ខ្លួន ហើយ កំពុងចោទប្រកាន់គ្នាទៅវិញទៅមក។ តាមពិត សីហនុ សមរ៉ាំងស៊ី សុនសាន រ៉ាណារិទ្ធ ជាស៊ីម ហេង សំរិន ហ៊ុនសែន កែមសុខា និង អ្នករាជាកុម្មុយនិស្ត ទាំងនេះឯង ដែលនាំគ្នាតាក់តែងដោយស្ងាត់ៗ រៀបចំឱ្យមានរាជាណាចក្រទី២ នេះឡើងវិញ ក្រោម ការ ប្រសិទ្ធីពរ ជ័យ នៃប្រទេសយួនដែលលួចញញឹមសង្ឃឹម ថានឹងអាចកាត់យកទឹកដីទាំងដុំៗ ជារង្វាន់ទៀតនៅពេលបន្ទាប់មក។ ដើម្បីលាងកំហុសក្បត់ខ្លួនឯង ហ៊ុនសែនបានលើកឡើងថាការងារនេះជាកិច្ចការដែលសីហនុមិនបានធ្វើ ពីពេលមុនហើយធ្លាក់ជាអំរែកលើស្មា របស់ ខ្លួន ។ តែហ៊ុនសែន ខ្លួនឯងគ្មានសេចក្តីក្លាហាន និងគ្មានប្រាជ្ញា ដើម្បី យកការងារនេះទៅ ដោះស្រាយ នៅ ចំពោះមុខ សហគមន៍ អន្តរជាតិទេ។ ចំណែក សីហនុ វិញ ដើម្បី រក្សាការពារបុព្វសិទ្ធិ រាជបល្ល័ង្គ ផ្ទាល់ខ្លួន គាត់មិនដែលហ៊ាន ដោះស្រាយ ការងារនេះដោយក្លាហានទេ នៅពេលដែលគាត់មានអំណាចគ្រប់បែបយ៉ាងក្នុងកណ្តាប់ដៃ។ ហើយកគួរឱ្យអនិច្ចាដែរ ហ៊ុនសែន ក៏មិនបានដោះស្រាយកិច្ចការព្រំប្រទល់ឱ្យបានជាប្រយោជន៍នៃមាតុភូមិខ្លួនដែរ គឺគ្រាន់តែបំរើជាកញ្ជះអាយ៉ងយួនដើម្បីធ្វើឱ្យការ កាត់យកទឹកដីខ្មែរមានភាពពិតប្រាកដជាក់ស្តែងដោយ ពុំបានពឹងផ្អែកលើច្បាប់អន្តរជាតិ ទេ។ គឺនៅក្នុងបរិបទនេះហើយ ដែលគេយល់រឹត តែច្បាស់ថា ហេតុអ្វី បានជាពលរដ្ឋខ្មែរ ឈប់មានជំនឿ លើក្រុមអ្នករាជាកុម្មុយនិស្តទាំងនេះ

(គឺបក្ស ប្រជាជន និង បក្សសង្គ្រោះជាតិ) ដើម្បីរំដោះប្រទេសកម្ពុជា ដោយខំពន្យល់ ឱ្យ គេទៅបោះឆ្នោតនៅថ្ងៃ២៨ កក្កដា ឆ្នាំ២០១៣។

## ៣-តើអ្នកណាដែលអាចបញ្ចៀស ភាពមិនអាចវិលត្រឡប់ក្រោយនៃយួនូបនីយកម្មនេះបាន?

គឺប្រជាពលរដ្ឋខ្មែរនេះឯង។ តាមរយៈ ការធ្វើបដិវត្តន៍។ ពុំមែនដោយការបោះឆ្នោតនៅថ្ងៃ២៨កក្កដា ឆ្នាំ ២០១៣ នោះទេ។ គួរឱ្យស្តាយ! មកទល់ថ្ងៃនេះ ប្រជាពលរដ្ឋខ្មែរមានឥរិយាបទ ដូចហ្វូងចៀមដែល នាំគ្នាដើរ តាមបញ្ជារ មេគង្វាល ដោយ គ្មានរារែក។ ភាព កំសោយជា ហ្វូង១ បែបនេះ ហើយ ដែលបណ្តាលឱ្យមាន ការ ប្រល័យពូជសាសន៍ខ្មែរ ជាង៣ លាននាក់ ក្រោម របបប៉ុលពត និងមានការបាត់បង់ ទឹកដី ដ៏សន្ធឹកសន្ធាប់ក្រោមរបបរាជានិយមទី២ ព្រមទាំងបានទទួលមហន្តរាយ មួយ ទៀត គឺអំណាចផ្តាច់ការបក្សប្រជាជន ហ៊ុនសែន សព្វថ្ងៃ ដែល អនុញ្ញាតឱ្យយួនកុម្មុយនិស្តមកកាត់យកទឹកដីនៃ មាតុភូមិ របស់ខ្លួន។ បើប្រជា ពលរដ្ឋក្រោកឡើងទាំងអស់គ្នា នោះប្រជាពលរដ្ឋ នឹងឈ្នះ! គ្មានអ្វីអាចមកប្រឈមមុខប្រជាពលរដ្ឋបានទេ។ យួនមិន ខ្លាច បក្សប្រជាជនហ៊ុនសែន ទេ ។វា មិនខ្លាច រាជានិយមសីហនុទី២ នេះទេ ហើយវាក៏មិនខ្លាច អ្នកនយោបាយខ្មែររាជាកុម្មុយនិស្ត និយម នៃ បក្សសង្គ្រោះជាតិ នោះដែរ។ យួនវាខ្លាចតែ ប្រជាពលរដ្ឋខ្មែរ ជាពិសេសវាខ្លាច បដិវត្តន៍នៃពលរដ្ឋខ្មែរ តែម្តង។ ព្រោះថា កិច្ចព្រមព្រៀង ប៉ារីស ថ្ងៃ២៣តុលាឆ្នាំ១៩៩១ មិនទាន់ស្លាប់ដូចដែលជនរាជាខ្មែរកុម្មុយនិស្ត ២នាក់គឺ ស៊ីសុវត្ថិ និង ខៀវ កាញ៉ារិទ្ធ អះអាងនោះទេ។ ទោះជាកិច្ចព្រមព្រៀងហ្សឺណែវ ឆ្នាំ១៩៥៤ ស្តីពីឥណ្ឌូចិនក៏ចិតនៅជា ធរមាន នៅឡើយដែរ។ គឺយួន ឈ្លានពាន និង អ្នកនយោបាយ ខ្មែរក្បត់ជាតិទេ ដែលជាន់ឈ្លីមិនគោរពកិច្ចព្រមព្រៀងទាំងនេះ។ ដូច្នេះ ការបោះឆ្នោត នៅថ្ងៃ២៨ កក្កដា ឆ្នាំ២០១៣ គឺសំរាប់តែ ធ្វើឱ្យយួនូបនីយកម្ម និង អំណាចផ្តាច់ការអាចអូសបន្លាយឱ្យ បានវែងបន្ត ទៀតតែ ប៉ុន នោះ។ សំណើរ កែប្រែដែលទាក់ទងត្រឹមតែការបោះឆ្នោតធ្វើឡើងដោយ លោកសុរិយ៉ា ស៊ូប៊ីឌី ប្រេសិតពិសេស នៃ អង្គការសហប្រជាជាតិ ពុំអាចនាំឱ្យមានដំណោះស្រាយ ក្នុងការរំដោះជាតិ និង រំលំ អំណាចផ្តាច់ការបានទេ។ ហ៊ុនសែន ដោយខ្លួន ជាជនក្បត់ជាតិស្រាប់ ក៏បែរជាហ៊ានអះអាងចំអកពីការ ផ្តេផ្តាចិត្ត របស់ ខ្មែរ១កម្ពុជា ក្រោម ដើម្បី ទាមទារយក ស្វ័យភាព នៃ ដែនដីកូសាំងស៊ីន មកវិញ ព្រោះបារាំងបានប្រគល់ ឱ្យយួន ចៅដាយ នៅថ្ងៃ៤ មិថុនាឆ្នាំ ១៩៤៩ ពេល ដែលគេគ្រប់ គ្រង ខ្មែរ ធ្វើជាអាណា ព្យាបាល និង អាណានិគម។ ហ៊ុនសែន គួរសិក្សាបន្ថែម ពី ប្រវត្តិ សាស្ត្រសម័យថ្មី ដើម្បី ឱ្យបាន ដឹងថាតើមាន រដ្ឋ ប៉ុន្មានហើយ ក្នុងលោកនេះ ដែលបាន ដណ្តើមបានយក ឯករាជ្យ របស់ខ្លួន មកវិញចាប់ ពីមាន ការ កកើតនៃ អង្គការ សហប្រជាជាតិមក។ ហើយប្រហែល មានតែ ហ៊ុនសែន ម្នាក់គត់ នៅចុង សតវត្សរ៍ ទី២០ និងនៅ ដើម សតវត្សរ៍ ទី២១ នេះ ដែល បានប្រើអំណាចផ្តាច់ការលើប្រជាជាតិឯង ហើយ កាត់ទឹកដីទៅឱ្យយួន ទោះជា មានកិច្ចព្រមព្រៀង អន្តរជាតិ នៅ ថ្ងៃ២៣ តុលា ឆ្នាំ១៩៩១ ជួយធានានិង គាំទ្រប្រជាជាតិខ្មែ និង ប្រទេសកម្ពុជាក៏ដោយ។ ហ៊ុនសែន អន់ជាង សាដាំ ហ៊ូសេន កាដាហ្វី និង បាហ្សារអែលឡាសាដ ឆ្ងាយណាស់ ព្រោះ ជនផ្តាច់ការទាំង៣ នេះ គេ ជាអ្នក ជាតិនិយមមិនមែនជាជន ក្បត់ជាតិខ្លួនឯងទេ។

ពេលវេលាកាន់តែខិតណាស់ហើយ។ ដើម្បីបញ្ចៀសភាពដែលមិនអាចវិលត្រឡប់វិញបាននៃយួនូបនីយកម្ម បដិវត្តន៍ផ្កាឈូក បានតាក់តែង យុទ្ធវិធីរបស់ប្រជាពលរដ្ឋ ដែលអាចឱ្យគេនាំមកវិញបាន នូវសេចក្តីសង្ឃឹមពិតប្រាកដ ទោះបីជាមាន ឧបសគ្គ សន្ធឹកសន្ធាប់ ដែល សត្រូវ បង្ករដាក់រាំងនៅតាមផ្លូវរបស់គេក៏ដោយ។

ខាងក្រោមនេះគឺជា ដំណាក់ការ ២:

១ /,ប្រជាពលរដ្ឋត្រូវតែ ផ្ដួលរំលំចន្ទល់ ទាំងអស់នៃរបបផ្ដាច់ការ តាមគ្រប់ មធ្យោបាយ ។ ចន្ទល់ទាំងនេះ ហើយដែលជា ប្រភពនៃទុក្ខវេទនារបស់ប្រជាជន។ ចន្ទល់ទាំងនេះ បានទទួលការ គាំទ្រគ្រប់បែបយ៉ាងពីរបបផ្ដាច់ការ ហើយពុំដែលត្រូវបានទទួល ទណ្ឌកម្ម ពីសំណាក់ របបផ្ដាច់ការទេ ។នៅតាមប្រទេសនានា ដែល មាន បដិវត្តន៍ ចន្ទល់ទាំងអស់ នៃរបបផ្ដាច់ការ ដួលរលំម្ដងមួយៗ ។ ចន្ទល់យោធារ និង ចន្ទល់ ការទូត តែងរត់ចោលជួរដោយ យឺតយ៉ាវ គឺនៅខាងចុងបដិវត្តន៍ តាមបែបផែនរត់ចោលជួរជាបុគ្គល ឬ ជា ក្រុមៗ ដើម្បី ពង្រីកកំលាំង ជួរអ្នកបដិវត្តន៍។ បើចន្ទល់ នានាទាំងអស់ រង្គោះរង្គើហើយ នោះរបបផ្ដាច់ការនឹងរលំដួលដោយឯកឯង។

២/,បើប្រជាពលរដ្ឋពុំអាចសំរេចបានជោគជ័យ ទាំងស្រុងក្នុងដំណាក់ការទី១ នេះទេ (ព្រោះអំណាចផ្ដាច់ការ មានទំហំធំធេងពេក) គេនៅមានពេលធ្វើ មហាពហិការជាទូទៅ និង ជាបញ្ចប់ គឺមិនទៅបោះឆ្នោត យ៉ាងគគ្រឹកគគ្រេង នៅថ្ងៃ២៨កក្កដាឆ្នាំ ២០១៣។ គេនឹងអាច ទទួលជោគជ័យ បានយ៉ាង ពិតប្រាកដ ព្រោះពលរដ្ឋអាចឈោងចាប់យកជោគជ័យនេះបាន ហើយជាការស្របតាមការ វិវឌ្ឍន៍នៃពិភព លោក ទៀតផង។ ប្រជាពលរដ្ឋនឹងនាំគ្នា ធ្វើសកម្មភាពនេះ តាមបែបផែនជា ក្បាលម៉ាស៊ីនអូសទាញ កំលាំងស្នេហាជាតិ ។ បើរបប ផ្ដាច់ ការ ដួល រលំ នោះការរត់ចោលជួរ នៃចន្ទល់ គាំទ្រនានា ក៏នឹងកើតមានឡើងដែរតាមយន្តការ បញ្ច្រាសទៅ បញ្ច្រាស មក។ ទោះក្នុង ករណីណាក៏ដោយ ក៏ ក្រុមប្រឹក្សាជាតិអន្តរកាល នៅតែ សំរាំងសំរួចយុទ្ធវិធីនៃការបះបោរ បន្តទៀត។ នៅក្នុងដំណាក់ជឿន លឿនខ្លាំងទៅមុខនៃ បដិវត្តន៍ រដ្ឋាភិបាលបណ្ដោះអាសន្នអន្តរកាលមួយនឹង ត្រូវបង្កើតឡើង ដើម្បី រ៉ាប់រងតាក់តែងឱ្យមានរបបមួយ ដែល ប្រជា ពលរដ្ឋចង់បាន។

## ៤-ពេលដែលត្រូវសំរេចចិត្ត

*បងប្អូនរួមជាតិជាទីគោរព*

យើងត្រូវ ហ៊ានដឹកកប់របបរាជាកុម្មុយនិស្តខ្មែរក្រហមក្បត់ជាតិសព្វថ្ងៃ។ ការសន្យាមុនពេលបោះ ឆ្នោតនៃ អ្នក នយោបាយរាជាកុម្មុយនិស្ត (បក្សប្រជាជន និង បក្សសង្គ្រោះជាតិ) គឺជា នយោបាយនយោបោក។ ប្រជាពលរដ្ឋខ្មែរបានខាតបង់ ពេលវេលា បាត់បង់ជីវិត និង បាត់បង់ ទឹកដី ជាច្រើនសន្ធឹកសន្ធាប់ណាស់ មកហើយ។ យើងត្រូវតែហ៊ានបង្កើតរបបថ្មី មួយ ដោយឈរ លើគ្រឹះនានា ដែលជាតំលៃ សាកលនៃសង្គមមនុស្ស ហើយដែលយើង បានស្គាល់ និង កំពុង ស្គាល់ នៅតាម ប្រទេសនានាក្នុងប្លុក ខាងលិច។ មានតែ ការធ្វើ បដិវត្តន៍ផ្កាឈូកដោយអហឹង្សា (មហាបាតុកម្មស៊ូណាមិដៃកាន់ ផ្កាឈូក និងធូប) នេះទេដែលអាច នាំ ឱ្យ ប្រជា ពលរដ្ឋ ខ្មែរ សំរេចបំណងនេះបាន។

### ១-បោះឆ្នោត ថ្ងៃ២៨កក្កដា២០១៣?

យើងសាកប្រមើលមើលស្ថានភាពប្រទេសកម្ពុជានៅក្រោយ ថ្ងៃ២៨កក្កដា២០១៣:

ក,/ បក្សប្រជាជនហ៊ុនសែន នឹងឈ្នះ ជាដាច់ខាត ព្រោះគេមានចន្ទល់ ហើយបើទោះជាមានការកែទំរង់ គជប ក៏ដោយ។ សំណើរពង្រាងច្បាប់ ស្ដីពីហិរញ្ញប្បទាននៃការបោះឆ្នោត ដែលគាំទ្រដោយ អង្គការក្រៅរដ្ឋាភិបាល ៤ មាន ខុមហ្វ្រែល និចហ្វិច ឌីអេតវ៉ាក់ និង ស៊ីសា គ្មានសំណាងថាបក្សប្រជាជននឹងទទួលយកទេ។ និយាយឱ្យខ្លី គឺអ្វីៗទាំងអស់នឹងឋិតនៅដដែល

ហើយ គ្មានអ្វីដែលនឹងប្រែលទេ ទោះជា អំពើផ្ដាច់ការ យួននិគមូបនីយកម្ម និង អនិតិរដ្ឋ ក៏ដោយ។ មហាគ្រោះថ្នាក់ដល់ស្លាប់ ឬ ភាពមិនវិលត្រឡប់ក្រោយ វិញ នៃយួនូបនីយកម្ម នឹង បន្តដំណើរទៅមុខទៀត។

ខ,/ បក្សសង្គ្រោះជាតិឈ្នះ(ដែលជាសម្មតិកម្មមិនប្រាកដនិយម) ឬ បានទទួលសំឡេងច្រើនជាងមុន ។ ពេលនោះ អ្វីៗ ក៏ នឹងនៅដដែលទាំងអស់ដែរ។ ពីព្រោះអ្វីៗទាំងអស់ ថិតនៅក្នុងកណ្ដាប់ដៃ បក្សប្រជាជនរួចទៅហើយ។ បក្សសង្គ្រោះជាតិ នឹង គ្មាន បានកាន់កាប់អ្វីទាំងអស់។ ពេលនោះគឺពិតជាខ្យល់ព្យុះនៅក្នុងកែវទឹកមែន។ យួននិគមូបនីយកម្ម នឹង រឹតតែរឹងមាំ។ អំណាចផ្ដាច់ការ បក្សប្រជាជនហ៊ុនសែន នឹង រឹងរឹតតែខ្លាំង។ ពេលនោះហើយដែលគេនាំគ្នាស្រងាកចិត្ត។ ព្រោះព្រឹទ្ធសភា ថិតនៅក្នុងកណ្ដាប់ ដៃបក្សប្រជាជនរួចមកហើយ (៤៨ អាសនៈ) រីឯ បក្សសមរ៉ាំងស៊ីមានតែ ១១អាសនៈ ទេ។ បក្សប្រជាជនមាន មេឃុំ ១៥៩២ ចំណែកបក្ស ប្រឆាំងមានតែ ៤០ អាសនៈ ប៉ុននោះ។ គណបក្សសង្គ្រោះជាតិ អាចនឹងឈ្នះបាននិតិបញ្ញត្តិ បន្តិចបន្តួច បន្ថែមទៀត ក៏ប៉ុន្តែប្រទេស និង ប្រជា ពលរដ្ឋនឹងទទួល រងការឈឺចាប់បន្តទៀត។ ដូច្នេះ បក្សសង្គ្រោះជាតិ នាំយើងចូលលេងល្បែងជាមួយ បក្ស ប្រជាជនកញ្ជះ យួន ដោយ មិនហ៊ាន និយាយប្រាប់យើងឱ្យត្រង់ៗ ថាខ្លួនគ្មានក្ដីសង្ឃឹមថា នឹងរំដោះប្រទេសកម្ពុជាបានទេ។ ប្រធានាធិបតី បាហ្សា អែល អាសាដ ក៏បានប្រើវិធីបង្ខំ ឱ្យមាន ការបោះឆ្នោតដែលគ្មានភាពប្រាកដនិយម ក្នុងពេលកំពុង មាន ការយុទ្ធគ្នាដូច្នេះដែរ។ ហើយគាត់ បាន ឈ្នះការបោះឆ្នោត ទាំង នោះទៀតផង។ ក៏ប៉ុន្តែប្រជាពលរដ្ឋស៊ីរី មិនបានទទួលយក លទ្ធផលនៃការបោះ ឆ្នោត ទាំងនេះទេ។ ប្រជា ពល រដ្ឋ ទុយនីហ្ស៊ី អេហ្ស៊ីប និង លីប៊ី គេនាំគ្នាជ្រើសរើយក បដិវត្តន៍ប្លែកៗ ពិសេស ផ្ទាល់ តាមលក្ខណៈ ប្រជា ជាតិគេនិមួយៗ។ ប្រទេស កម្ពុជាបានត្រូវយួន កាត់យក ទឹកដីរួចមកហើយ។ ប្រជា ពល រដ្ឋខ្មែរ ត្រូវតែហ៊ានបង្កើត បដិវត្តន៍ពិសេស ផ្ទាល់ខ្លួនមួយ។ ជាពិសេស ប្រជាពលរដ្ឋ ខ្មែរមិនត្រូវ ជឿទុកចិត្ត អ្នកនយោបាយ រាជា កុម្មុយនិស្តខ្មែរ ក្រហម ដែលបានក្បត់ជាតិខ្លួនជាង២១ឆ្នាំ រួចមកហើយនេះទេ។

## ២-បដិវត្តន៍ផ្កាឈូក?

បដិវត្តន៍ផ្កាឈូកមាន យុទ្ធវិធី ៤ដំណាក់:

១/, កំចាត់យួននិគមូបនីយកម្មឱ្យបានមុនដំណាច់ ឆ្នាំ២០១២ ដើម្បីរក្សាទុកសំណាងបញ្ចៀសភាពមិនអាច វិលត្រឡប់វិញបាននៃយួនូបនីយកម្ម។ ២/, រំលំរបបផ្ដាច់ការឱ្យបានមុនថ្ងៃ២៨កក្កដាឆ្នាំ២០១៣ ដើម្បីជៀសឱ្យបានកុំផ្ដល់និតិបញ្ញត្តិឱ្យបក្សប្រជាជនទៀត។ ៣/, ពេលយើងរំលំរបបផ្ដាច់ការ និង ដេញយួនបានសំរេចហើយ យើងនឹងកសាងរបបមួយដែល ប្រជាពលរដ្ឋចង់បាននៅក្នុងប្រទេសកម្ពុជា។ ៤/, រៀបចំការបោះឆ្នោតដោយសេរី។

### ក/-បើចន្ទល់ដួលរលំហើយអំណាចផ្ដាច់ការ នឹង រលាយដោយឯកឯង

ចន្ទល់ទាំងនេះ មានរូបភាពជា បុគ្គល ជា ស្ថាប័នរដ្ឋ ជាអង្គការឧក្រិដ្ឋកម្ម និង ជា រដ្ឋបរទេស តាមរយៈ ជំនួយរបស់គេ មាន ប្រទេសចិន និង យួន ជាដើម។ ពេលណា ចន្ទល់ទាំងនេះដួលរលំហើយ ដោយអហឹង្សា មហាគ្រឹះនៃរបបនេះ នឹងដួលរលំ ស្រុត ធ្លាក់ ចុះ ដោយ ឯកឯង។

សព្វថ្ងៃនេះ ស្ថាប័នរដ្ឋទាំងអស់ថិតក្នុងកណ្ដាប់ដៃបក្សប្រជាជនហ៊ុនសែន។ អង្គរក្សផ្ទាល់ របស់ហ៊ុនសែន មានពី៥ ទៅ៧ ពាន់នាក់។ ទាហានយួនស្លៀកពាក់ជាស៊ីវិល មានចំនួនជាង ១សែននាក់ បើតាមការ សារភាពរបស់ហ៊ុនសែន។ នៅមាន និគមជនយួន ដែលកាន់អត្តសញ្ញាណប័ណ្ណជាតិ និង ប័ណ្ណបោះឆ្នោត។ មាន អ្នកបោះឆ្នោតចល័ត មកពីស្រុកយួននៅថ្ងៃបោះឆ្នោតផងដែរ។ ទាហាន យួន ជាអ្នកជំនាញ និង ជំនួយការ នៅក្នុងរដ្ឋបាលជាចំហរ និង ខ្លះទៀតលាក់មុខ ដែលបាន និង កំពុងទទួល ដីសម្បទាន

ដាំកៅស៊ូ និង ដី កសិកម្ម តាមបណ្តោយព្រំប្រទល់ មានរយៈពេលពី ៧០ ឆ្នាំទៅ៩៩ឆ្នាំ ដែលនៅទីនោះ គេប្រើប្រាស់ប្រជាជនយួនផ្តាច់មុខ។ សេដ្ឋកិច្ច ទេសចរវប្បធម៌ អង្គរ គ្រប់គ្រងដោយ សុខ គង់។ ការដឹក ជញ្ជូនតាមអាកាស មាន អាកាសចរខ្មែរអង្គរ និង អាកាសចរ វៀត ណាម។ ផ្នែកធនាគារ គឺមាន ធនាគារបណ្តាក់ទុន និង អភិវឌ្ឍន៍ កម្ពុជា និង ធនាគារបណ្តាក់ទុន និង អភិវឌ្ឍន៍ វៀតណាម។ ឧស្សាហកម្ម ទូរគមនាគមន៍ គឺ ម៉េតហ្វូន និង វៀតតែល។ សំណង់ អាគារ ម៉ាស៊ីនយន្ត កសិកម្ម គឺ ក្រុមហ៊ុន កៅស៊ូវៀតណាម និង ក្រុមហ៊ុន ហ្សិត៣៨ ។ នេសាទ ពាណិជកម្ម ចែកចាយ (ផ្សារម៉លំស៊ីវធី)។ សេវាពេទ្យក៏ឋិតក្នុង កណ្តាប់ ដៃយួនដែរ។ ចំនួន ជនជាតិយួន យ៉ាងហោចណាស់ក៏មានពី ៥ ទៅ៧លាននាក់។ សខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ពុំដែល ហ៊ាន បដិសេដ្ឋ ឬ ទទួលយល់ព្រម លើតួរលេខនេះទេ។ តុលាការនៅក្រោមការបង្គាប់បញ្ជារ ហ៊ុនសែន ដែលប្រើ ស្ថាប័ន នេះ ដើម្បី ចោទប្រកាន់អ្នកនយោបាយ ប្រឆាំង និង អ្នកបំរើការងារឱ្យអង្គការក្រៅរដ្ឋាភិបាល។ ហ៊ុនសែន បានបង្គាប់ឱ្យគេ ចាប់ លោក ម៉ម សុណង់ដូ យកទៅដាក់គុក ដោយចោទប្រកាន់ដាក់បន្ទុក ៤ ករណី ក្នុងនោះមានការ ញុះញុងនាំបង្កើតតំបន់ អបគមន៍ ជាដើម។ ចំណែក ឈូកបណ្ឌិត អភិបាលស្រុក បាវិត ដែលជាមនុស្សរបស់លោកស្រី ម៉ែនសំអាន ឧបនាយករដ្ឋមន្ត្រី ទទួលបន្ទុក គណកម្មការ មិត្តភាព ខ្មែរយួន និង សរ ខេង ឧបនាយករដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ ហើយដែលបានបាញ់ឱ្យមានរបួស កម្មការិនី ៣នាក់ នៅក្នុង រោងចក្រ សំលៀក បំពាក់ នៅ ខេត្ត ស្វាយ រៀង ឋិតនៅក្រៅឃុំដដែល ពុំទាន់ត្រូវបានគេចាប់ចងនៅ ឡើយ ទេ។ ហ៊ុនសែន គ្រប់គ្រង ប្រភពថវិការ រដ្ឋ និង ឯកជន ទាំងអស់ គ្រប់គ្រាន់ដើម្បីជួលសេវាពិសេសផ្នែកទ័ព ដើម្បីការពារខ្លួន (អង្គរក្ស ផ្ទាល់ខ្លួនឋិត នៅក្រោម ការដឹកនាំរបស់កូនគាត់ ហ៊ុន ម៉ាណែត )។ ហ៊ុនសែន បានប្រើប្រាស់សហព័ន្ធនិស្សិត និង បញ្ញវន្តនៃកម្ពុជា និង សមាគម សិស្ស និស្សិត និង បញ្ញវន្តក្មេងវត្ត ដើម្បី ព្រមានអ្នកធ្វើការ ក្នុងអង្គការក្រៅរដ្ឋាភិបាលដូចលោក ស៊ា ភារុន នៃក្រុម ការពារសិទ្ធិ លំនៅឋាន និង បុគ្គលិកនៃ មជ្ឈមណ្ឌល សិទ្ធិ មនុស្សកម្ពុជា មិនឱ្យបន្តការងារជួយ អ្នកភូមិ បឹងកក់ បូរីកីឡា និង ប្រជាជន ដ៏ទៃទៀត ដែលគេបណ្តេញចេញពីលំនៅឋាន នៅទូទាំងប្រទេសទៀតទេ។ អង្គការក្រៅ រដ្ឋាភិបាល ចំនួន ២១ មាន CCHR, CCIM, CICA, CDP, CFSWF, CHRAC, LICADHO, CWCD, CYN, CCFC, COMFREL, CLEC, CPN, CCC, CARAM, HRTF, IDEA, KYA, LAC, PAC, STT ) បានតវ៉ាប្រឆាំងការចោទ ប្រកាន់គ្មានមូលដ្ឋានទៅលើ លោក ចាន់សូវេត នៃ សមាគមអាដហុក ពី បទសមគំនិតជាមួយលោកប៊ុនរដ្ឋា ដែល ហ៊ុនសែន ចោទដោយកំរោលថាជា អ្នកធ្វើ អបគមន៍ នៅខេត្ត ក្រចេះ។ ហ៊ុនសែន គ្រប់គ្រងបញ្ហាប្រទេសតាមតែបបូរមាត់ គាត់ ដោយមិន គោរពច្បាប់ អ្វីទាំងអស់ ដូចជា បង្កើត កង ឯកភាព និស្សិតស្ម័គ្រចិត្ត ដឹកនាំដោយ កូនប្រុសគាត់ឈ្មោះ ហ៊ុនម៉ានិត ដើម្បី ដោះ ស្រាយបញ្ហាដីធ្លី និង សុរិយោដី ហើយដែលបំផុស ប្រតិកម្ម អវិជ្ជមាន បន្ថែមជាច្រើនទៀត។ អ្វីៗទាំងអស់ឋិតនៅក្នុងដៃគាត់ ដូចជា កូនប្រុសគាត់ឈ្មោះ ហ៊ុនម៉ាណែត កាន់កាប់មុខងារជា មេបញ្ជាការរងនៃកងទ័ពខ្មែរ។ ក្មួយ ប្រសារគាត់ឈ្មោះ នេតសាវឿន ទទួលកាន់កាប់ប៉ូលីស។ កងអង្គរក្ស របស់គាត់ និង កងអង្គភាពប្រឆាំងអំពើភេរវកម្មឋិតនៅក្រោមការ គ្រប់គ្រងរបស់ ហ៊ុន ម៉ាណែត។ ស្ថាប័នដ៏ទៃទៀត ដូចជា នគរ បាល តុលាការ គជប ឃុំ ស្រុក ខេត្ត ព្រឹទ្ធសភា សភាជាតិ ក្រុមប្រឹក្សារាជបល្ល័ង្គ ក្រុមប្រឹក្សាធម្មនុញ្ញ គឺឋិតនៅ ក្នុង ដៃបក្ស ប្រជាជន ទាំងអស់។ គេត្រូវបញ្ចូលកងឯកភាពប្លែកៗ ច្រើនទៀត ដែល នៅក្រោម អំណាច សុខអាន និង បុគ្គល ខ្លាំងៗ ដ៏ទៃ ទៀត នៅក្នុង សេដ្ឋកិច្ច ដូចជា ប្រេងកាត កសិកម្ម ព្រៃឈើ កៅស៊ូ ឧស្សាហកម្ម ពាណិជកម្ម ។ល។ សង្គមកិច្ច រដ្ឋបាល និង ផ្នែកផ្សេងៗ ទៀត ដូចជា ឯកភាពប្រឆាំងអំពើពុករលួយ សារពតិមាន និង ប្រតិកម្ម រហ័ស ទូរទស្សន៍ វិទ្យុ សារពតិមាន រដ្ឋ និង ឯកជន។ .ដូច្នេះគេអាចប្រមាណមើលឃើញ ពីអានុភាពប្រយុទ្ធដ៏ ធំធេង នៃ ចន្ទល់ ទាំងអស់នេះ ដែល ប្រើប្រាស់ថវិការ មកពីគ្រប់ មជ្ឈដ្ឋាន មាន

ការលក់អាភៀន ការកាប់ ព្រៃឈើ អំពើ ពុករលួយ ការប្រើប្រាស់បង្ខៃង ដាននូវ មូលនិធិនានា ប្រាក់ចំណូក និង កំចីរដ្ឋ និង បំណុលនានា ដែលពុំមានការគ្រប់គ្រង ត្រឹមត្រូវ ពិតប្រាកដ ម៉ាហ្វ៉ា ។ល។ ទាំងអស់នេះ ហើយ ដែលជាអង្គហេតុ ដែល ជំរុញ ឱ្យ ចលនាអំណាច ពលរដ្ឋខ្មែរ នៃ លោក សួន សេរីរដ្ឋា ដាក់ពាក្យបណ្ដឹង របបហ៊ុនសែន ពី បទឧក្រិដ្ឋកម្ម ប្រឆាំង មនុស្សជាតិ ,,, ។ល។ កាលពី ថ្ងៃ ២២មិថុនា ឆ្នាំ ២០១២ ទៅ តុលាការព្រហ្មទ័ណ្ឌ អន្តរជាតិ នៅទីក្រុង ឡាអេ ក្នុង ប្រទេសហុលឡង់។ ជាការពិត និង ជាការ ចំឡែកដែរ ព្រោះ ប្រទេសកម្ពុជា ក្លាយជាប្រទេស សំរាប់លក់!។

ខ/-បើចន្ទល់មិនទាន់រលំទេ មហាពហិការ និង ស៊ូណាមីរំដោះ និង ធ្វើសកម្មភាពបន្ត

បើប្រជាពលរដ្ឋធ្វើការផ្ដួលរំលំចន្ទល់ទាំងអស់នេះ បានសំរេច នោះ របបផ្ដាច់ការនឹងដួលរលំដោយឯកឯង។ ពេលនោះ ប្រជាពលរដ្ឋពុំចាំបាច់នាំគ្នាធ្វើ មហាពហិការលើការបោះឆ្នោតថ្ងៃនៃក្នែកនោះទេ។ រដ្ឋាភិបាលបណ្ដោះអាសន្នមួយ នឹងត្រូវ បង្កើត ឡើង ដើម្បីអនុវត្តវិធានការចាប់ ជនឧក្រិដ្ឋ ជនក្បត់ជាតិ និង ជនពុករលួយ។ ជ័យជំនះនេះហើយដែលនឹង ជួយសំរួលជា យថាហេតុ នូវ កិច្ច ការរបស់ តុលាការព្រហ្មទ័ណ្ឌអន្តរជាតិ។ តែបើប្រជាពលរដ្ឋមិនទាន់ បានសំរេចការ កាប់ផ្ដួលរំលំចន្ទល់ ទាំងនេះទេ គេនៅមាន ពហិការ ដ៏ធំធេងជាបញ្ចប់ ទៀតដើម្បីប្រមូលឱ្យបាន ២/៣ ឬ ៤/៥ នៃ អ្នកចុះឈ្មោះបោះឆ្នោត។ ពេលនោះហើយ ដែលរបប បក្ស ប្រជា ជន អស់សិទ្ធិដឹកនាំប្រទេសបន្តទៀត។ ប្រជាពលរដ្ឋនឹងក្លាយដោយឯកឯងជាអ្នក កាន់កាប់ អំណាច។ ពេលនោះ សហគមន៍ អន្តរ ជាតិនឹងត្រូវតែកត់សំគាល់ និង ទទួលស្គាល់ឥថភាពនេះ។ ប្រទេសចិន និង ប្រទេសយួនក៏ត្រូវតែ ទទួល ស្គាល់ ហើយ ពិចារណា លើ ឥថភាពនេះដែរ។ ជ័យជំនះរបស់ បដិវត្តន៍ផ្កាឈូក គឺជាជ័យជំនះ របស់ប្រជាពលរដ្ឋទាំងអស់ ដែលបានជួយ អនុវត្ត ឱ្យយុទ្ធវិធី បដិវត្តន៍ផ្កាឈូក សំរេចបាន។ ខ្មែរក្រៅស្រុក និងខ្មែរក្នុងស្រុក ត្រូវតែរួមសាមគ្គីគ្នាឱ្យបានជាក់ស្ដែងដើម្បីធ្វើឱ្យ បូជនីយ កិច្ចរំដោះ ជាតិបានទទួលជោគជ័យ។ គឺ មានតែនៅក្នុងគោលដៅ នេះទេ ដែលខ្មែរត្រូវនាំគ្នាបង្កើត និង ស្វែង រកមូលនិធិ ដើម្បី រំដោះជាតិ។ ព្រោះ គេ មានល្បិច និងមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីធ្វើឱ្យបានជោគជ័យ តាមអ៊ីម៉េល ហ្វេសប៊ុក ទូរទ័រ វីដេអូ បាតុកម្ម ស៊ូណាមី និង ថវិការ ,,,។

*បងប្អូនរួមជាតិជាទីគោរព!*

យើងមិនអាចទទួលយក បរាជ័យនៃ បដិវត្តន៍ផ្កាឈូក បានទេ ព្រោះគឺជាបរាជ័យប្រទេសកម្ពុជា និងពលរដ្ឋខ្មែរ នៅ ចំពោះ មុខប្រទេសយួន និង នៅចំពោះ មុខរបបផ្ដាច់ការហ៊ុនសែន។ ដើម្បីទាមទារឱ្យបានមកវិញនូវឯករាជភាព និង បូរណភាព ទឹកដី ប្រជា ពលរដ្ឋ ខ្មែរមាន ជំរើសតែ មួយគត់ គឺធ្វើ សង្គ្រាមរំដោះជាតិដោយខ្លួនឯង តាមលក្ខណះពិសេស ស្អាត មិនប្រឡាក់ ឈាម ។ ដើម្បី សំរេចបាន ជាដំបូង ប្រជាពលរដ្ឋខ្មែរ ត្រូវផ្ដួលរំលំចន្ទល់ទាំងអស់នៃរបបនេះសិន ដោយអហឹង្សា។ ចន្ទល់ ទាំងនេះ ខ្លះជា ឯកជន ខ្លះ ជា ស្ថាប័ន ជាសីលធម៌ ជាហិរញ្ញវត្ថុ ជាកំលាំងទ័ព ហើយ ចន្ទល់ខ្លះ គឺបរទេសផ្ដល់ឱ្យ ដូចជា ចិន និង យួន ជា ដើម។ គឺតាមការ លុបបំបាត់ចោល ឬ ផ្ដួលរំលំ ចន្ទល់ ទាំង នេះ ហើយ ដែល ប្រជាពលរដ្ឋខ្មែរ អាច កំចាត់ អំណាច ផ្ដាច់ការ បាន ។ យោង តាមកិច្ចព្រមព្រៀង ហ្សឺណែវឆ្នាំ ១៩៥៤ តាមកិច្ចព្រមព្រៀងសន្តិភាព ប៉ារីស ថ្ងៃ២៣ តុលា ១៩៩១ តាម ការប្រកាសជា សាកល នៃសិទ្ធិមនុស្ស និង ស្រប តាម រដ្ឋ ធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ ប្រជាពលរដ្ឋមិនត្រូវ ទទួលយក ភាព ជាក់ស្ដែង ដែល យួនបង្កើត នៅហ្នឹងកន្លែងដូច សព្វថ្ងៃ នេះទេ ហើយជា ពិសេស មិនត្រូវសង្ឃឹមទុកចិត្ត លើអ្នកដឹកនាំ រាជាកុម្មុយនិស្ត ក្បត់ជាតិទៀត ឡើយ។ ឧបករណ៍អន្តរជាតិ ដ៏សែនមានតំលៃ គឺកិច្ច ព្រម ព្រៀងប៉ារីស នេះ នឹងក្លាយជាវត្ថុ ឥតប្រយោជន៍ បើសិនជា កិច្ច ព្រម ព្រៀងប៉ារីស មិនបាន ជំរុញ ខ្មែរឱ្យ យកមកធ្វើ ជាឧបករណ៍ សំរាប់ រំដោះ

មាតុភូមិ ទេ។ បើយើងមិនធើបបះបោរទេ  សហគម អន្តរជាតិនឹង មិនធ្វើការងារ នេះ ជំនួសយើង ឡើយ។  ពេលទទូល បាន ជ័យជំនះ បដិវត្តន៏ផ្កាឈូក នឹងប្រកាសលុបចោល នូវ សន្ធិសញ្ញា ទ្វេភាគី ខ្មែរ យួនឆ្នាំ ១៩៧៩-១៩៨២-១៩៨៨៣-១៩៨៨៥ និង  សន្ធិសញ្ញា បំពេញបន្ថែម ២០០៥ ហើយ ប្រកាសមិនទទួលស្គាល់បង្គោលព្រុំដែន ៣៧៥ ដែលយួនបាន បោះ នៅលើ ព្រុំប្រទល់ រួមប្រវែង ១២៧០គម ស្របតាម សន្ធិសញ្ញាខ្មែរយួនទាំងនោះទេ។  ដោយយោងតាម សន្ធិ សញ្ញានៃ ក្រុង ហ្សឺណែវ ឆ្នាំ១៩៥៤  និង តាម កិច្ច ព្រមព្រៀង ប៉ារីស ថ្ងៃ២៣តុលា ឆ្នាំ១៩៩១  បដិវត្តន៏ ផ្កាឈូក  នឹងដាក់ជូន សហគមន៏ អន្តរជាតិ នូវបញ្ហា ព្រុំប្រទល់ខ្មែរ ដោយ យក ផែនទីដែល ប្រទេស កម្ពុជា បានដឹកល់ទុកនៅ អង្គការ សហប្រជាជាតិ ជាមូលដ្ឋាន ពេល ដែលប្រទេសខ្មែរ បានចូល ជាសមជិក ពេញលេញ នៃអង្គការនេះ ក្រោយពីទទួលបាន ឯករាជ្យនៅឆ្នាំ១៩៥៣មក។


អ៊ូ ចល

សមាជិកស្ថាបនិក- បដិវត្តន៏ផ្កាឈូក

បណ្ឌិតទស្សនវិជ្ជា សាកលវិទ្យាលយស៊័របោន ប៉ារីស

DEA de Philosophie- Sorbonne  Paris

បណ្ឌិតពតិមានវិទ្យាឯកសារ សាកលវិទ្យាល័យលីយ៉ុង១ និង អិនស៊ីប

DESS Informatique Documentaire-
Lyon I & ENSSIB


***********************************